**អង្គរបុរី**
**សម្លេងខ្មែរនៅបរទេស**

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ការអភិវឌ្ឍន៍ព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរនិងជួយខ្មែរនៅប្រទេសវៀតណាមនិងប្រទេសថៃឲ្យរក្សាវប្បធម៌របស់ខ្លួនបាន ។

website: www.hoksavann.org
ថ្ងៃទី២២ មករា ២០០៨



១- ការអភិវឌ្ឍន៍ព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរ

ការអភិវឌ្ឍន៍ព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរ ជាពិសេសការបង្កើតវត្ត ពុំមែនមានប្រយោជន៍តែព្រះពុទ្ធសាសនាទេ គឺមានប្រយោជន៍ខាងការធ្វើជារបងការពារទឹកដីខ្មែរ រារាំងកុំឲ្យបរទេសរំកិលព្រំដែនចូលមកដីខ្មែរជាបន្តមកទៀត។ វត្តព្រះពុទ្ធសាសនាជាភស្តុតាងសំខាន់ណាស់ ដែលបញ្ជាក់ថាជាដីខ្មែរ ។ ពុទ្ធបរិស័ទខ្មែរនៅតាមព្រំប្រទល់ដែនមានការពិបាកខាងការប្រតិបត្តិព្រះពុទ្ធសាសនា ព្រោះពុំមានវត្តអារាមនៅជិត ហើយកន្លែងខ្លះមានវត្តក៏ពុំមានសេនាសនៈគ្រប់គ្រាន់ដូចជាកុដិសាលាព្រះវិហារជាដើម និងមិនមានព្រះសង្ឃអ្នកចេះដឹងនិមន្តទៅគង់នៅទីនោះផង ។ ដូច្នេះ ដើម្បីពង្រឹងព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរឲ្យបានលូតលាស់ចំរើន និងដើម្បីជារបងការពារទឹកដីខ្មែរ រដ្ឋាភិបាលនិងពុទ្ធបរិស័ទខ្មែរដែលមានសទ្ធា គួរជួយកសាងវត្តនៅកន្លែងដែលមានខ្មែររស់នៅ បើកន្លែងដែលមានវត្ត តែគ្មានសេនាសនៈគ្រប់គ្រាន់គួរជួយកសាងបន្ថែម ។ សព្វថ្ងៃនេះ តាមដំណឹងថា មានពុទ្ធបរិស័ទខ្លះបានជួយកសាងវត្តនៅជាយដែនខ្លះហើយ ។ មួយទៀត ដើម្បីឲ្យពលរដ្ឋខ្មែរពេញចិត្តទៅរស់នៅតាមជាយដែន ឲ្យបានច្រើន គួរធ្វើហេដ្ឋារចនាសម្ពន្ធ ដូចជាផ្លូវថ្នល់ស្ពាន សាលារៀន មន្ទីរពេទ្យ បង្កើតផ្សារជាដើម ឲ្យដូចជានៅទីប្រជុំជន ។ ព្រោះប្រទេសជិតខាង តែងរំកិលចូលមកត្រង់ដីទំនេរដែលគ្មានខ្មែររស់នៅនេះឯង ។ មួយទៀត បើបានធ្វើផ្លូវថ្នល់ព័ទ្ធជុំវិញព្រំប្រទល់ដែនជា

ខ្មែរក្រវ៉ាត់ រឹតតែប្រសើរណាស់ទៅទៀត ព្រោះបានជាទំនប់ទប់មិនឲ្យបរទេសរំលោភចូលមកដីខ្មែរបាន ។ វត្តអារាមជាដួងព្រលឹងរបស់ខ្មែរ បើមានខ្មែររស់នៅទីណា តែងមានវត្តអារាមនៅទីនោះ ជាទីគោរពសក្ការៈរបស់ខ្លួន ។ ដូច្នេះវត្តទុកជាភស្តុតាងដែលបញ្ជាក់ថា ជាទឹកដីខ្មែរ ។ ប្រយោជន៍មួយទៀត បើមានវត្តព្រះពុទ្ធសាសនានៅតាមចុងកាត់មាត់ញកដូច្នេះ អាចជួយបងប្អូនជនជាតិភាគតិច ដែលមានបំណងគោរពព្រះពុទ្ធសាសនា បងប្អូនអាចគោរពបានដោយងាយស្រួល ព្រោះមានវត្តនៅជិតផ្ទះខ្លួន ហើយមិនទុកឱកាសឲ្យសាសនាដទៃចូលមកជ្រៀតជ្រែកបានផង ។

២- <u>អំពីវាសនានៃខ្មែរកម្ពុជាក្រោម</u>

នៅសម័យមហានគរ ខ្មែរមានទឹកដីធំទូលំទូលាយ មានអារ្យធម៌ដ៏ខ្ពង់ខ្ពស់ ហើយជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងផង ។ សតវត្សក្រោយមក ទឹកដីខ្មែរខ្លះបានត្រូវបាត់បង់ទៅលើប្រទេសជិតខាងបច្ចុប្បន្ន គឺប្រទេសវៀតណាមនិងប្រទេសថៃ ។ ទឹកដីខ្មែរកម្ពុជាក្រោមបានធ្លាក់ទៅលើប្រទេសវៀតណាមទាំងស្រុងនៅថ្ងៃទី៤ មិថុនា ១៩-៤៩ ។ បងប្អូនខ្មែរកម្ពុជាក្រោមបានខំប្រឹងប្រែងរក្សាវប្បធម៌នៅលើទឹកដីកំណើតរបស់ខ្លួន មានព្រះពុទ្ធសាសនានិងអក្សរសាស្ត្រជាដើមយ៉ាងខ្លាំងក្លាបំផុត ទោះបីត្រូវវៀតណាមធ្វើបាបរំលោភច្បាប់ជាតិច្បាប់អន្តរជាតិក៏ដោយ ។ ចំណែករដ្ឋាភិបាលខ្មែរស្ទើរគ្រប់ជំនាន់ មិនសូវយកចិត្តទុកដាក់ក្នុងការទាមទារទឹកដីដែលបានបាត់បង់ និងការពារជនជាតិរបស់ខ្លួន ដែលត្រូវវៀតណាមធ្វើបាបឡើយ ។ ពិសេសរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះ មិនត្រឹមតែមិនជួយការពារពលរដ្ឋរបស់ខ្លួនទេ ថែមទាំងបញ្ជូនពលរដ្ឋរបស់ខ្លួន គឺព្រះគ្រូទឹម-សាខន ឲ្យវៀតណាមកាត់ទោស ។ សព្វថ្ងៃនេះ ពលរដ្ឋខ្មែរ ទាំងខ្មែរលើទាំងខ្មែរក្រោមមានការព្រួយបារម្ភថា ពលរដ្ឋខ្មែរណាដែលជាមុខសញ្ញាត្រូវកំចាត់ គេគ្រាន់តែចោទថា ធ្វើឲ្យខូចមិត្តភាពខ្មែរ-វៀតណាមប៉ុណ្ណោះ គេអាចបញ្ជូនខ្មែរនោះឲ្យវៀតណាមកាត់ទោស ដូចករណីព្រះគ្រូទឹម-សាខន ។ ឥឡូវនេះ បងប្អូនខ្មែរកម្ពុជាក្រោមមានសិទ្ធិខាងផ្លូវច្បាប់ ក្នុងការទាមទារសិទ្ធិក្នុងឋានៈជាម្ចាស់ដើមនៃទឹកដី ដើម្បីសំរេចនូវវាសនាខ្លួនដោយខ្លួនឯងហើយ ដោយកាលពីថ្ងៃ១៣ កញ្ញា ២០០៧ សមាជិកនៃអង្គការសហប្រជាជាតិចំនួន១៤៤ប្រទេស ប្រជុំគ្នាអនុម័តច្បាប់ពិសេសមួយ គឺច្បាប់នៃជនជាតិដើមដែលគ្មានតំណាងនៅក្នុងអង្គការសហប្រជាជាតិ ។ ច្បាប់នោះ មាន៤៦មាត្រា ជាពិសេសមាត្រាទី៣ជាមាត្រាសំខាន់ ក្នុងន័យឲ្យជនជាតិដើមមានសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង ។ សព្វថ្ងៃនេះ តំណាងជនជាតិដើមដែលគ្មានតំណាងនៅក្នុងអង្គការសហប្រជាជាតិមាន៦៩ប្រទេសជាសមាជិក , ក្នុងចំណោម៦៩ប្រទេសនោះ មាន៥ប្រទេសបានទទួលឯករាជ្យ ។ សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក ដែលបានបង្កើតឡើងនៅថ្ងៃ៨កក្កដា១៩៩៦ ជាតំណាងពេញច្បាប់នៃខ្មែរកម្ពុជាក្រោម ។ ដូច្នេះខ្មែរកម្ពុជាក្រោម មានសិទ្ធិ

ខាងផ្លូវច្បាប់អន្តរជាតិ ក្នុងការសំរេចវាសនាខ្លួនដោយខ្លួនឯង មានការរក្សាការពារនូវវប្បធម៌របស់ខ្លួនមានព្រះពុទ្ធសាសនាជាដើម ។

៣- អំពីវាសនានៃជនជាតិខ្មែរនៅប្រទេសថៃ

ខ្មែរបានត្រូវបាត់បង់ទឹកដីទៅប្រទេសថៃជាច្រើនខេត្ត ដូចជាខេត្តនៅនិយាយភាសាខ្មែរ គឺខេត្តបុរីរាម ខេត្តសុរិន្ទ ខេត្តកូខាន់ និងខេត្តស៊ីសាកេត ។ ចំណែកខេត្តខ្មែរដែលបានទៅថៃរហូតមកទល់ពេលនេះ ស្ទើរតែបាត់បង់ភាសាខ្មែរ ដែលជាភាសាកំណើតរបស់ខ្លួន គឺខេត្តចន្ទបូ ខេត្តត្រយង់ ខេត្តបស្ទឹមបុរី និងខេត្តនគររាជសីមា ។ រដ្ឋាភិបាលខ្មែរស្ទើរតែគ្រប់ជំនាន់ ក៏ពុំបានគិតគូរអំពីទឹកដីដែលបានបាត់បង់ទៅថៃឡើយ ។ មិនតែប៉ុណ្ណោះ សូម្បីតែធ្វើសំណើទៅរាជរដ្ឋាភិបាលថៃ ឲ្យខ្មែរនៅថៃរៀនភាសាខ្មែរ ដើម្បីកុំឲ្យបាត់បង់ភាសាកំណើត និងទំនៀមទម្លាប់ប្រពៃណីខ្មែរ ក៏រដ្ឋាភិបាលខ្មែរពុំដែលគិតគូរសោះឡើយ ។ តាមឯកសារខ្លះថា ទឹកដីខ្មែរដែលបានបាត់បង់ទៅថៃ មានទំហំ៦០,០០០ គ.ម.[២] មានចំនួន១០ខេត្ត មានពលរដ្ឋខ្មែររស់នៅចំនួន៧លាននាក់ ។ ខ្មែរអាយុក្រោម៤០ឆ្នាំមិនចេះនិយាយខ្មែរឡើយ ព្រោះកុមារាកុមារីខ្មែរត្រូវតែចូលរៀនសាលារដ្ឋរបស់ថៃ ។ សព្វថ្ងៃគេនៅពូចម្រៀងខ្មែរសុរិន្ទ ហៅថាចម្រៀងកន្ទ្រឹម ។ នៅពេលថ្មីៗនេះ លោកជ័យមង្គលអាយុ៨១ឆ្នាំ ភរិយាឈ្មោះអក្ខរា និងទារិកាម្នាក់ដែលទើបនឹងកើតឈ្មោះអប្សរា ជាគ្រួសារខ្មែរមកពីខេត្តកូខាន់ បានបើកបង្រៀនភាសាខ្មែរពីរកន្លែងនៅខេត្តសុ-រិន្ទ ។ យើងសូមសរសើរ និងសូមអនុមោទនានូវឧត្តមគតិជាតិនិយមដ៏ជ្រាលជ្រៅរបស់លោកជ័យមង្គល ដែលបានបើកបង្រៀនភាសាខ្មែរនេះ ។ ជាមួយគ្នានេះ យើងសូមអំពាវនាវរដ្ឋាភិបាលខ្មែរ និងពលរដ្ឋខ្មែរកណ្តាល សូមជួយជំរុញការសិក្សាភាសាខ្មែរនេះឲ្យបានជោគជ័យ ដោយយកលោកជ័យមង្គលជាគំរូ ព្រោះសកម្មភាពនេះស្របតាមច្បាប់អង្គការសហប្រជាជាតិក្នុងឋានៈជាម្ចាស់ដើមនៃទឹកដី ។៚

❄ ❄

❄